## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
លេខ:០១១ /០៨ របក. អ.គ.គ

## របាយការណ៍ សិក្ខាសាលា
## ស្តីពីការអនុម័តសេចក្តីព្រាងលើលក្ខណៈវិនិច្ឆ័យសម្រាប់តុលាការគំរូកម្ពុជា
## នៅសណ្ឋាគារសាន់វ៉េ

ឆ្នាំពីរពាន់ប្រាំបី ខែ កុម្ភៈ ថ្ងៃទី ម្ភៃប្រាំបី វេលាម៉ោងបីកន្លះនៅសាលប្រជុំរបស់សណ្ឋាគារសាន់វ៉េ ដោយ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ បានរៀបចំសិក្ខាសាលាមួយ ស្តីពីការអនុម័តសេចក្តីព្រាង លើលក្ខណៈវិនិច្ឆ័យសម្រាប់តុលាការគំរូកម្ពុជា ក្រោមអធិបតីភាពរបស់ឯកឧត្តម ស៊ុយ ម៉ុងលាង នាយក អង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់មកជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម ស៊ុយ ម៉ុងលាង បានថ្លែងអំណរគុណចំពោះអ្នកចូលរួមទាំងអស់ ហើយជាបន្ទាប់ ឯកឧត្តមបានរំលឹកឡើងវិញនូវការបង្កើតតុលាការគំរូចំនួន៤ខេត្តក្រុង ដូចជា ក្រុងភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ចាម និងខេត្តបន្ទាយមានជ័យ ។ ក្នុងរបៀបវារៈនោះ ឯកឧត្តមបានស្នើសុំអោយក្រុមការងារយើង ពិនិត្យឡើងនូវអ្វីដែលក្រុមការងារ យើងបានចុះក្នុងឯកសាររបស់យើង ថាតើវាមានលក្ខណៈគ្រប់គ្រាន់ហើយ ឬនៅ ? បើមិនទាន់គ្រប់គ្រាន់ទេ យើងនឹងយកការពិភាក្សាគ្នាថ្ងៃនេះមកបញ្ចូលក្នុងឯកសារបន្ថែមទៀត ។ ហើយបន្ទាប់មកយើងត្រូវពិនិត្យមើលទៅលើសំណួរ ដោយផ្អែកទៅលើលក្ខណៈទាំងបីមាន ស្តង់ដារ គោលការណ៍ និងលក្ខណៈវិនិច្ឆ័យ ទាក់ទងនឹងស្តង់ដារនេះ គឺយើងមិនមានការកែប្រែនោះទេគ្រាន់តែពិនិត្យឡើងវិញតែប៉ុណ្ណោះ ហើយស្តង់ដារទាំង១១ យើងជ្រើសរើសយកតែមួយ ដែលជាស្តង់ដារអន្តរជាតិ ដែលអន្តរជាតិគេ ទទួលយកចំណែកលក្ខណៈវិនិច្ឆ័យក៏ជ្រើសរើសយកជាលក្ខណៈអន្តរជាតិ ដោយយកឧបករណ៍អន្តរជាតិទាំងប៉ុន្មានដាក់បញ្ចូលទៅក្នុងឯកសារ ។ ឆ្លៀតក្នុងឱកាសនោះដែរ ឯកឧត្តមបានអញ្ជើញឯកឧត្តម ហេង ជី ជាក្រុមប្រឹក្សាអ្នកច្បាប់ មានមតិយោបល់បន្ថែមទាក់ទងទៅនឹងតុលាការគំរូនេះ ឯកឧត្តមប្រធានក៏បាន

បញ្ជាក់ផងដែរថា ការអញ្ជើញឯកឧត្តម ហេង ជី មកចូលរួមសិក្ខាសាលាថ្ងៃនេះគឺធ្វើយ៉ាងណាដើម្បីអោយតុលាការ គំរូរបស់យើងនៅមានលក្ខណៈជាខ្មែរ។

ឯកឧត្តម ហេង ជី ជាក្រុមប្រឹក្សាអ្នកច្បាប់ បានមានប្រសាសន៍ថា ក្នុងវិស័យកែទម្រង់ច្បាប់ និងតុលាការនេះ ឯកឧត្តមបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការចូលរួមចំណែកក្នុងរឿងតុលាការគំរូនោះ ដើម្បីអោយមានដំណើរការទៅមុខ ។ ក្នុងនោះដែរឯកឧត្តមក៏បានឯកភាព ទៅលើអនុសាសន៍របស់ឯកឧត្តម ប្រធានអង្គសិក្ខាសាលាខាងលើនោះដែរ ។

លោក Thomas Trier ចៅក្រមនៃតុលាការជាន់ខ្ពស់មកពីប្រទេសដាណឺម៉ាក បានធ្វើការផ្តោតអារម្មណ៍ ទៅលើឯកសារស្តីពីតុលាការគំរូថា វាពិតជាមានសារៈសំខាន់ណាស់ ដែលលោកបានចូលរួមសិក្ខាសាលា នាថ្ងៃនោះ ហើយលោកសង្ឃឹមថា យើងនឹងមានយោបល់លើឯកសារទាំងនេះ ។

ជាបន្ទាប់ អង្គសិក្ខាសាលាបានមូលមតិគ្នាធ្វើការត្រួតពិនិត្យ ឡើងវិញនូវការវិភាគតុលាការគំរូកម្ពុជា ដែលមានដំណាក់កាលរឿងក្តីទាំង១០ដំណាក់កាល ដែលមានទិសដៅ ស្តង់ដារ គោលការណ៍ និងលក្ខណៈ វិថ្ន័យ លើកមកធ្វើការពិនិត្យឡើងវិញក្នុង១ដំណាក់កាលម្តងៗ ដូចខាងក្រោមនេះ ៈ

១ – <u>ដំណាក់កាលទទួលប្រជាពលរដ្ឋ /ដំណាក់កាលរឿងក្តី</u> **មានពីរផ្នែក គឺ ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី**

ផ្នែកព្រហ្មទណ្ឌមានមានការកែប្រែឡើងវិញត្រង់ស្តង់ដារទី១១ ៖ ត្រង់លក្ខណៈវិនិច្ឆ័យចេញពីច្បាប់ និងបទបញ្ញាតិ ត្រូវបន្ថែមក្នុងមាត្រាទី៥ មាត្រាទី៦ និងមាត្រាទី៧២ ៉ ត្រង់ចំណុចអ្នកបកប្រែ ៉ ។ ចំណែកស្តង់ដាទី៥ លក្ខណៈវិនិច្ឆ័យ ត្រង់បន្ថែមត្រង់បណ្តឹងទៅចៅក្រមស៊ើបអង្កេត ដូរទៅស៊ើបសួរវិញ – បណ្តឹងទៅនគរបាល ៉ នគរបាលយុត្តិធមិ ៉ បណ្តឹងទៅ ព្រះរាជអាជ្ញា ៉ បណ្តឹងអាជ្ញា (មាត្រាទី២២ នៃច្បាប់ព្រហ្មទណ្ឌ ) ។ ចំពោះស្តង់ដារទី៣ វិញ មាត្រាទី៩៨នៃក្រមព្រហ្មទណ្ឌ មានអ្នកបកប្រែ និងវេជ្ជបណ្ឌិត ចំណែកមាត្រាទី១០៣ ត្រូវបន្ថែម ក្នុងលក្ខណៈវិនិច្ឆ័យ ។

ទាក់ទងនឹងស្តង់ដារទី៥ នេះ លោក Thomas Trier បានសួរចំនួនពីរសំណួរថា តើតុលាការធ្វើការ ២៤ម៉ោង ឬក៏មានម៉ោងកំណត់ច្បាស់លាស់ ? មួយសំណួរទៀត ឧទាហរណ៍ថា បើសិនជាគាត់មានបញ្ហារឿងក្តី ហើយចង់ប្តឹង តើគាត់អាចទៅប្តឹងនៅកន្លែងណា ? ឆ្លើយតបនឹងសំណួរនេះ ឯកឧត្តមប្រធានអង្គសិក្ខាសាលាបានមាន ប្រសាសន៍ថា ចំពោះម៉ោងធ្វើការ និងចំពោះថ្ងៃឈប់សម្រាកបុណ្យទានខាងតុលាការក៏ដូចជាខាងក្រសួងដ៏ទៃៗទៀតដែរ ចំណែកបញ្ហាពាក្យបណ្តឹងវិញ ចំពោះបណ្តឹងរឿងព្រហ្មទណ្ឌ គឺមានព្រះរាជអាជ្ញា ឬនគរបាលយុត្តិធមិ ប្រចាំ២៤ម៉ោង ដូច្នេះ គឺអាចដាក់ពាក្យប្តឹងដោយផ្ទាល់ទៅព្រះរាជអាជ្ញា ឬនគរបាលយុត្តិធមិតែម្តង ។

លោក Thomas Trier បានសួរសំណួរថា តើក្រឡាបញ្ជីមានក្រមសីលធមិអ្វីដែរ ដែលថាគាត់មិនត្រូវបាន ទទួលសំណូកផ្សេងៗនៅពេលទទួលពាក្យបណ្តឹង ? ចំពោះសំណួរនេះ ឯកឧត្តមប្រធានបាន

បកស្រាយថា យើងមិនទាន់មានក្រមសីលធម៌របស់ក្រឡាបញ្ជីនៅឡើយទេ ប៉ុន្តែនៅតាមតុលាការនីមួយៗមានប្រធានរបស់គាត់ជាអ្នកត្រឹមត្រូវ ។

លោក អាំង មាលតី ប្រធានតុលាការខេត្តបន្ទាយមានជ័យ បានលើកឡើងថា កន្លងមកក្រឡាបញ្ជីបានចុះក្នុងបញ្ជីដោយឡែកៗខុសពីគ្នា និងត្រូវបង់ពន្ធផ្សេងគ្នា ។

ទាក់ទងនឹងស្តង់ដារទី៣ ក្នុងដំណាក់កាលទី១ ត្រង់ចំណុចថា ត្រូវបញ្ជូនអ្នកជាប់ចោទទៅភ្លាម លោក Thomas Trier បានសួរសំណួរថា ក្នុងពេលនោះតើជនជាប់ចោទអាចរកមេធាវីបានទេ ?

លោក ប្លង់ ឆ្លាម ប្រធានតុលាការខេត្តកំពង់ចាម បានឆ្លើយថា ករណីបែបនេះអ្នកជាប់ចោទអាចរកមេធាវីបាន ប៉ុន្តែបញ្ហាត្រូវឃុំខ្លួនគឺត្រូវតែឃុំ មិនអាចអោយនៅក្រៅឃុំបានទេ ។

លោក កើត វណ្ណារ៉េត ព្រះរាជអាជ្ញរង អមតុលាការខេត្តកណ្តាល សុំបន្ថែមមាត្រា ៥៤០ នៃក្រមរដ្ឋប្បវេណី ចូលទៅក្នុងស្តង់ដារទី៥ផងដែរ ។

**២-ដំណាក់កាលការចុះបញ្ជីពាក្យបណ្តឹង/ការទាមទារ**

ចំពោះរឿងក្តីព្រហ្មទណ្ឌមាន ស្តង់ដារ ទី៥.៨.១១ ហើយក្នុងស្តង់ដារទី១១នេះ គឺត្រូវបន្ថែមមានត្រា ៥.៦ និង ៧២ នៃក្រមព្រហ្មទណ្ឌក្នុងតារាង ។ ចំណែករឿងក្តីរដ្ឋប្បវេណី ស្តង់ដារទី៥ .៨ និង១១ ហើយចំពោះ ស្តង់ដារទី៥ លោក អាំង មាលតី បានលើកឡើងទាក់ទងនឹងបណ្តឹងឧបាស្រ័យថា អាចទាក់ទងនឹងលក្ខណៈ វិនិច្ឆ័យនៃស្តង់ដារនេះ ។ ជាបន្ទាប់ លោកបានបកស្រាយពីការចុះបញ្ជី ដែលមានចំនួនបួន គឺ ១-ការចុះបញ្ជី សំណុំទឹកប្រាក់តិច ២-ការចុះបញ្ជីសំណុំធម្មតា ៣-ការចុះបញ្ជីសំណុំដាស់តឿន និង៤-ការចុះបញ្ជីសំណុំរឿង រក្សាការពារ ។

ទាក់ទងនឹងដំណាក់កាលទី២ការចុះបញ្ជីពាក្យបណ្តឹង ចំពោះរឿងរដ្ឋប្បវេណី លោក Thomas Trier បានមានសំណួរថា ត្រង់ចំណុចនៃការចុះបញ្ជី និងបង់ពន្ធនៅពេលចុះបញ្ជីនោះ ថាតើមានត្រាណាខ្លះ ដែល តម្រូវថា កំណត់បង់ពន្ធដើម្បីឱ្យមានតម្លាភាព ?

ឆ្លើយតបនឹងសំណួរនេះ អង្គសិក្ខាសាលាបានពិនិត្យឃើញថា ចំពោះបញ្ហាដែលចោទសួរឡើងខាងលើនេះ ចំពោះពាក្យបណ្តឹងត្រូវបានកំណត់ក្នុងមាត្រា៦១.៦២.៦៣ ។

ជាបន្ទាប់មកទៀត លោក Thomas Trier បានចោទសួរថា តើមាននីតិវិធីសម្រាប់ច្បាប់ក្ស័យធនដែរឬទេ ? ក្រោយពីលោកដឹងថា មិនទាន់មានច្បាប់នេះទេ លោកបានសំណូមពរអោយក្រុម ការងារឯកភាពគ្នាថាសម្រេចអោយអង្គ ភាពគ្រប់គ្រងគម្រោងជាអ្នកពិនិត្យមើលលើច្បាប់ក្ស័យធននោះ រួចយកមកដាក់បញ្ចូលក្នុងឯកសារ ព្រោះលោកយល់ថា ច្បាប់នេះសំខាន់ណាស់សម្រាប់តុលាការ ។ ក្នុងនោះដែរ

លោកបានសួរថា បិតននៅក្នុងច្បាប់ក្ស័យធននេះ តើអាចអោយតុលាការពាណិជ្ជកម្ម ជាអ្នកកាត់ក្តីដែរឬទេ ? លោកព្រះរាជ អាជ្ញារងអមតុលាការខេត្តកណ្តាល បានឆ្លើយចំពោះរឿងនេះ គឺមានពាក់ព័ន្ធដែរ ។

**៣-ដំណាក់កាលការពិនិត្យការទាមទារ/ ការអនុវត្តបណ្តឹងអាជ្ញា**

ទាក់ទងនឹងដំណាក់កាលទី៣នេះ លោក Thomas Trier បានសួរថា តើចៅក្រមស៊ើបអង្កេតអាចធ្វើការណែនាំដល់ព្រះរាជអាជ្ញាដែរឬទេ ?ខាងប្រធានតុលាការឆ្លើយថា មិនអាចទេ ។ ហើយទាក់ទងនឹងស្តង់ដារ ទី១១ ត្រង់ចំណុចថា តុលាការត្រូវធានាដល់សាធារណៈជននូវតម្លាភាព និងការអាចប្រើប្រាស់បាន លោក Thomas Trier បានសួរថា តើជា សាធារណៈក្នុងការ ជំនុំជំរៈក្តី តើប្រជាពលរដ្ឋអាចទៅមើលបានទេ ?

លោក ប្លង់ ឆ្លាម មានប្រសាសន៍ថា ប្រជាពលរដ្ឋមិនអាចទៅមើលបានទេ គឺមានតែមេធាវី និងចៅក្រមតែប៉ុណ្ណោះ ។ មួយវិញទៀតលោក Thomas Trier បានសួរទៀតថា បើមេធាវីធ្វើការឱ្យកូនក្តីដែលគ្មានប្រាក់ មិនសូវល្អ តើកូនក្តីអាចសុំផ្លាស់ប្តូរមេធាវីបានឬទេ ? លោកប្រធានតុលាការបានមានប្រសាសន៍ថាប្រាកដ ជាអាចសុំផ្លាស់ប្តូរបានតាមចិត្តរបស់កូនក្តីជាប់ចោទ ហើយលោកបានបញ្ជាក់ទៀតថា បើបទល្មើសចាប់ពី១ឆ្នាំ ឡើងទៅ គឺអាចឃុំខ្លួនបានតែបើបទល្មើសក្រោមពី១ឆ្នាំ គឺមិនអាចឃុំខ្លួនបានទេ ។

លោក អាំង មាលតី បានសុំបន្ថែមមាត្រាទី ២៤៧ ២៤៩ និង២៥០ ។

ទាក់ទងនឹង **ដំណាក់កាលទី៩ៈ ការបិទបញ្ជីរឿងក្តី** ឯកឧត្តម ស៊ុយ ម៉ុងលាង បានចោទសួរ ជាសំណួរថា តើហេតុអ្វីបានចាំបាច់បិទបញ្ជីបែបនេះ ?

លោក អាំង មាលតី បានឆ្លើយតបថា ការបិទបញ្ជីនេះ គឺដើម្បីរក្សាទុក ឬបញ្ជូនទៅសាលាឧទ្ធរណ៍ អាស្រ័យ ទៅលើគេប្តឹង ឬមិនប្តឹង ។

លោក ប្លង់ ឆ្លាម ក៏មានប្រសាសន៍បន្ថែមទៀតថា កាលណាគេជំនុំជំរៈហើយចៅក្រម ដែលជានាយកក្រឡាបញ្ជី ត្រូវបញ្ជូនរឿងក្តីមកសាលាឧទ្ធរណ៍ ពេលនោះគឺចៅក្រមត្រូវអស់តួនាទី ក្នុងរឿងនេះហើយ ប៉ុន្តែបច្ចុប្បន្ននេះយើង មានបញ្ហាព្រោះថា យើងមិនទាន់មានបន្ទប់ទុកឯកសាររឿងក្តីនោះទេ ដូច្នេះហើយបាន ជារឿងក្តីនៅរ៉ាយប៉ាយតាមចៅក្រមនីមួយៗ ។ ជាមួយគ្នានោះដែរ ឯកឧត្តម គង់ ស្រ៊ីម អគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការសាលា បានចូលរួមមាន យោបល់ក្នុងរឿងនេះផងដែរថា ការបិទបញ្ជីនេះគឺមានពីរយ៉ាង ទី១-ការបិទដោយគេឈប់ប្តឹង ទី២-ការបញ្ចប់រឿងក្តី ដោយបញ្ជូនទៅសាលាឧទ្ធរណ៍ ។

ឯកឧត្តម ស៊ុយ ម៉ុងលាង បានមានប្រសាសន៍សរុបអង្គសិក្ខាសាលាទាំងមូល ដោយការព្រមព្រៀងឯកភាពគ្នាថា នឹងកែលើឯកសារទៅតាមអនុសាសន៍របស់អង្គប្រជុំ ហើយអង្គភាពគ្រប់គ្រងគម្រោងនឹងធ្វើការរៀបចំឯកសារនេះ ម្តងទៀតអោយបានឆាប់ ។ ពេលដែលចប់សព្វគ្រប់ហើយ យើងនឹងផ្ញើជូនដល់សមាជិកក្រុមការងារទាំងអស់ ព្រមទាំងបន្តការដាក់ជូនទៅក្រុមការងារជាន់ខ្ពស់ ដើម្បីពិនិត្យ និងអនុម័ត ។ ចំពោះ ឯកសារសំណួរឯកឧត្តមសន្យាថា នឹងរៀបចំ ផ្ញើជូនទៅតាមក្រោយ ។

អង្គប្រជុំពិភាក្សាបានបញ្ចប់នៅវេលាម៉ោងប្រាំ៧ យប់ នាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៨*

បានឃើញ និងឯកភាព

ប្រធានអង្គប្រជុំ　　　　　　　　　　　　អ្នកធ្វើរបាយការណ៍

ស៊ុយ ម៉ុងលាង　　　　　　　　　　　　សេង វ៉ាន់ដា　　　　ស៊ុន សិរីវុធ

បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា
នាថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៨

១- ឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង

២- ឯកឧត្តម ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោង

៣- ឯកឧត្តម ចន្ទ័ មនោ នាយកខុទ្ធកាល័យ និងជាទីប្រឹក្សាអមក្រសួងយុត្តិធម៌ និងជាសមាជិក ( TWG )

៤-ឯកឧត្តម ខៀវ សាម៉េត ប្រធានតុលាការខេត្តកណ្តាល

៥-ឯកឧត្តម ឧត្តមសេនីយ៍ឯក ហេង ហាក់ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ

៦-លោក ឈឹម ស៊ីផល ចៅក្រមតុលាការកំពូល និង ជាសមាជិក ( TWG )

៧-លោក អ៊ីវ គឹមស្រ៊ី ចៅក្រមតុលាការក្រុងភ្នំពេញ

៨-កញ្ញា សៀក ធារី មន្ត្រី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

៩-លោក កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្តាល

១០- លោក វៀល សុភិន តំណាង ឯកឧត្តមប្រុក សារឿន ក្រសួងមហាផ្ទៃ

១១- Mr. Ben Schultz, Adviser (CCJAP III)

១២- លោក ជ សៀកវេង CCJAP

១៣- លោក បូន សុមុនី

១៤- កញ្ញា ហ៊ីង សុកុល អនុ ប្រធានក្រុមគម្រោងរដ្ឋបាល និងហិរញ្ញវត្ថុ

១៥- លោក ឆុង ហួត ប្រធានក្រុមគម្រោងកំណែទម្រង់ច្បាប់

១៦- លោក គង់ ផល្លៈ អនុប្រធានក្រុមគម្រោងកំណែទម្រង់ច្បាប់

១៧- លោក ឃ្លោក ដារ៉ា ប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឍត្តកម្ម

១៨- លោក កួយ សៅ អនុប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឍត្តកម្ម

១៩- លោក លោក ហូរ ភ័ត្រា មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ

២០- លោក សួន វីរៈ មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ

២១- លោកស្រី យិន កក្កដា មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ

២២- លោកស្រី សេង វ៉ាន់ដា មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ

២៣- កញ្ញា ផាន ពិសីនលក្ខណ៍ មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ